សប្តាហ៍ទី
44

ព្រះយេស៊ូយាងចូលក្រុងយេរូសាឡិម

ព្រះយេស៊ូបានគង់លើសត្វលា យាងចូលក្រុងយេរូសាឡិម។
តស់! យើងក៏ត្រូវកាន់ធាងចាកគ្រវី និងស្រែកថា "ហូសាណា!" ទាំងអស់គ្នា!

រឿងក្នុងព្រះគម្ពីរ

ព្រះយេស៊ូបានយាងទៅក្រុងយេរូសាឡិមជាមួយពួកសិស្ស។ មនុស្សម្នាបានកាន់ធាងចាកគ្រវីព្រមទាំងស្រែកថា "ហូសាណា! សូមសរសើរតម្កើងព្រះអង្គដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់!"។ ពាក្យថា "ហូសាណា!" មានន័យថា "សូមសង្គ្រោះយើងខ្ញុំផង!"។

ព្រះយេស៊ូបានគង់លើសត្វលា ហើយយាងចូលក្រុងយេរូសាឡិម ដោយមានការស្វាគមន៍ពីប្រជាជន។

យើងក៏ត្រូវមានចិត្តអំណរស្វាគមន៍ព្រះយេស៊ូ ដោយកាន់ធាងចាកគ្រវី និងសរសើរតម្កើងទ្រង់ដែរ។

«ហូសាណា!...សូមថ្វាយព្រះពរព្រះអង្គដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់!»
[ម៉ាថាយ ២១:៩]



វត្ថុបំណង

- យល់ពីរឿងរ៉ាវដែលព្រះយេស៊ូយាងចូលក្រុងយេរូសាឡិម។
- បង្ហាញពីក្តីអំណរក្នុងការទទួលស្វាគមន៍ព្រះយេស៊ូ តាមរយៈគំនិតច្នៃប្រឌិត
- អភិវឌ្ឍជំនាញផាត់ពណ៌ និងកាត់ក្រដាស ដើម្បីបង្ហាញពីអារម្មណ៍សប្បាយរីករាយ។

សម្ភារៈ

ក្រដាសកាតុង (ទំហំ A3) សម្រាប់ធ្វើផ្លូវ


ក្រដាសពណ៌


ខ្មៅដៃពណ៌, ពណ៌ហ្វឺត, កូល័រទៀន Oil pastels


កន្ត្រៃ


ការ


ក្រដាសព្រីនរូបព្រះយេស៊ូ

របៀបធ្វើសកម្មភាព

1. គូរផ្លូវនៅចំកណ្តាលក្រដាស ហើយត្រៀមខ្មុក។
2. គូររូបផ្ទះ ជញ្ជាំង ដើមឈើ និងពពក។
3. គូររុក្ខជាតិផ្សេងៗ រួចផាត់ពណ៌រូបទាំងអស់នោះ។
4. ផាត់ពណ៌រូបព្រះយេស៊ូ និងសត្វលា។
5. កាត់រូបព្រះយេស៊ូ និងសត្វលាតាមទម្រង់។
6. យករូបព្រះយេស៊ូទៅបិទនៅលើផ្លូវ ជាការស្រេច!



ការពង្រីកសកម្មភាព

- សាកល្បងប្រើប្រាស់សម្ភារៈផ្សេងៗ (ខ្មៅដៃពណ៌ កូលទៀន ពណ៌ហ្វឺត។ល។) ដើម្បីតុបតែងផ្ទះ និងផ្ទៃខាងក្រោយ។
- សហការជាមួយមិត្តភក្តិ ដើម្បីបង្កើតផ្លូវដ៏វែងមួយរួមគ្នា។
- សាកល្បងធ្វើរូបធាងចាក ឱ្យមានច្រើនម៉ូដ ច្រើនទម្រង់ប្លែកៗគ្នា។
- តាំងបង្ហាញស្នាដៃដែលបានរួចនៅលើជញ្ជាំង ហើយទស្សនាទាំងអស់គ្នា។
- សាកល្បងបង្កើតរូបធាងចាក ដើម្បីតុបតែងថ្នាក់រៀន និងដើម្បីរំលឹកដល់ការយាងចូលក្រុងយេរូសាឡិមរបស់ព្រះយេស៊ូ។

Tip សម្រាប់គ្រូ

- លោកគ្រូអ្នកគ្រូគួរតែគូរគំនូសផ្លូវនៅលើក្រដាសផ្ទាំងធំទុកជាមុន។
- សូមលើកទឹកចិត្តកុមារ ឱ្យគូរអគារ ដើមឈើ ភ្នំ មនុស្ស ជាដើម តាមការស្រមើស្រមៃរបស់ពួកគេដោយសេរី។
- សូមណែនាំឱ្យកុមារប្រើប្រាស់ពណ៌ និងរូបរាងផ្សេងៗគ្នាឱ្យបានច្រើន។
- សូមព្រីនរូបព្រះយេស៊ូឱ្យធំបន្តិច ដើម្បីឱ្យកុមារងាយស្រួលលាបពណ៌។
- ចំពោះកុមារតូចៗដែលពិបាកប្រើកន្ត្រៃ លោកគ្រូអ្នកគ្រូអាចជួយកាត់ឱ្យពួកគេបាន។
- ពេលធ្វើរួចរាល់ ទាំងគ្រូ និងកុមារគួរស្រែកពាក្យ "ហូសាណា!" ដើម្បីស្វាគមន៍ព្រះយេស៊ូទាំងអស់គ្នា!